00796550

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 04 / 2012
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

002/19-09-2007-ECCC/TC
E1/50

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៣៨

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង **Natacha WEXELS-RISER**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី , លោក ដាវ អានសាន, លោកស្រី Natacha WEXELS-RISER |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក វ៉េង ហ៊ត់, លោក William SMITH, លោក ពេជ្រ សម្បត្តិ, លោក Dale Lysak, កញ្ញា Golriz Ghahraman, |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ (អវត្តមាន), លោក Michiel Pestman, លោក Andrew IANUZZI, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael G. Karnavas |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង ធីរិទ្ធ៖ លោកស្រី Diana Ellis |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth Simonneau-Fort, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ស៊ិន សុវ៉ន, លោកស្រី ម៉ុច សុវណ្ណារី, លោក ហុង គីមសួន, លោកស្រី Lyma NGUYEN, លោក Barnabé NEKUIE, លោកស្រី ទី ស្រ៊ីនណា |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី Seynabou DIOP, លោកស្រី Nathalie TURCOVICH, លោក Laurent SOULARD |
| ផ្សេងៗ៖ លោក Philippe GOUT, លោក Dejan BERBEROVIC |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.00 | បញ្ចប់ម៉ោង៖ ១៦.១៥ (៧ ម៉ោង ១៥នាទី) |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.០៥ | បញ្ចប់ម៉ោង៖ ១១.00 (៥៥នាទី) |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.១០ | បញ្ចប់ម៉ោង៖ ១៤.១០ (៣ម៉ោង) |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៥.00 | បញ្ចប់ម៉ោង៖ ១៥.២០ (២០នាទី) |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៣ ម៉ោង | | |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីថ្លែងការណ៍របស់ នួន ជា និង សំណើសុំ និងការកត់សម្គាល់ដោយភាគី | មេធាវីការពារឲ្យ នួន ជា<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ៩.១៤ | ១០.00 |
| ការតាំងសំណួរទៅ នួន ជា ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ៩.៣៧ | ១១.០៦ |
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ និងស្នើសុំតាមដានដំណើរការនីតិវិធីពីបន្ទប់រង់ចាំ | មេធាវីការពារឲ្យ អៀង សារី<br>មេធាវីការពារឲ្យ នួន ជា | ១០.០៥<br>១២.០៣ | ១០.០៥<br>១២.០៣ |

| | | | |
|---|---|---|---|
| សំណើសុំទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតប | សហព្រះរាជអាជ្ញា | ១១.០៩ | ១៤.១០ |
| សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ១៤.១២ | ១៤.១៨ |
| ការតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅឌុច | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៤.១៨ | ១៦.០២ |
| ការពិភាក្សាលើសំណើសុំរបស់ សហព្រះរាជអាជ្ញាក្នុងការបង្ហាញនូវ ឯកសារពាក់ព័ន្ធនានានៅក្នុងសំណុំរឿងលេខ០០១ | សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារឱ្យ នួន ជា<br>មេធាវីការពារឱ្យ អៀង សារី | ១៦.០២ | ១៦.១៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការ និងជម្រាបសាធារណជនអំពីអង្គហេតុដែលត្រូវដេញដោលនៅក្នុងសវនាការវគ្គទី២នេះ។

**<u>សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា និងសំណើសុំ</u>**

ជនជាប់ចោទ នួនជា បានអាននូវសេចក្តីថ្លែងការណ៍ដែលមានភាពចាំបាច់សម្រាប់យោងទៅលើអង្គហេតុមុនឆ្នាំ ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ និងបានស្នើសុំឱ្យអង្គជំនុំជម្រះបន្តសវនាការទៅលើអង្គហេតុទាំងនោះ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ចំពោះសំណើសុំនេះ។

**<u>ការតាំងសំណួរដោយអង្គជំនុំជម្រះទៅជនជាប់ចោទ នួន ជា</u>**

អង្គជំនុំជម្រះបានចោទសួរទៅជនជាប់ចោទនួន ជា ចំពោះអង្គហេតុទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទ។ ជនជាប់ចោទនួនជា បានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរហូតដល់អង្គជំនុំជម្រះសម្រេចអំពីសំណើសុំខាងលើរបស់គាត់សិន។

**<u>សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះ</u>**

អង្គជំនុំជម្រះបានរំលឹកអំពីព្រឹត្តការណ៍ផ្សេងៗដែលបានកើតមាននៅក្នុងសវនាការពេលព្រឹក ហើយបានថ្លែងថា សកម្មភាពរបស់មេធាវីការពារឱ្យជនជាប់ចោទ នួន ជា គឺផ្ទុយទៅនឹងតួនាទីរបស់គាត់ដែលជាមេធាវីចំពោះតុលាការនេះ។ អង្គជំនុំជម្រះបានថ្លែងថាអាកប្បកិរិយានេះបានបង្ហាញឱ្យឃើញពីបញ្ហា

សីលធម៌ធ្ងន់ធ្ងរ ហើយអង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការចាត់វិធានការណាមួយចំពោះទង្វើទាំងនេះ។

**<u>សំណើសុំទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតប</u>**

សហព្រះរាជអាជ្ញាបានយោងទៅលើសំណើសុំរបស់គាត់ទាក់ទងជាមួយជនជាប់ចោទ ខៀវ សំផន អំពីផលវិបាកផ្សេងៗនៃការផ្តល់ចម្លើយទៅឱ្យតុលាការ និងបន្ទាប់មកបានបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ (ឯកសារ E174)។ សហព្រះរាជអាជ្ញាបានលើកឡើងថាបញ្ហានៅពេលនេះក៏អនុវត្តចំពោះជនជាប់ចោទ នួន ជាផងដែរ។ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា អង្គជំនុំជម្រះនឹងយកឯកសារ E164 (សំណើសុំរបស់មេធាវីការពារក្តី អៀង សារី ឱ្យច្រានចោលការទាញសេចក្តីសន្និដ្ឋានអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ) និង ឯកសារ E174 មកធ្វើការពិចារណានៅពេលដែលឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។

**<u>ការតាំងសំណួរទៅសាក្សីកាំង ហ្គេកអ៊ាវ ហៅ ឌុច</u>**

សហព្រះរាជអាជ្ញា បានចាប់ផ្តើមតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅឌុច។

**<u>ការពិភាក្សាលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញឯកសារពាក់ព័ន្ធនានានៅក្នុងសំណុំរឿងលេខ០០១</u>**

សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតិផ្តល់ឯកសារថតចម្លងកំណត់ហេតុស្តាប់ចម្លើយ និងឯកសារប្រតិចារិក ដែលសាក្សីបានឆ្លើយនៅក្នុងសំណុំរឿងលេខ០០១ ទៅឱ្យសាក្សីនៅមុនពេលដែលសួរសាក្សីទៅលើឯកសារទាំងនោះ។ អង្គជំនុំជម្រះបានសម្រេចថាសាក្សីអាចពិនិត្យមើលឯកសារទាំងនោះបានមុនពេលដែលត្រូវបានតាំងសំណួរទៅសាក្សីចំពោះឯកសារទាំងនោះ ដើម្បីរំលឹកសាក្សីឱ្យមានការចងចាំ

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣)</u>**

| លេខ អជសឈ | លេខ កសចអ លេខ ERN | ចំណងជើង | ចំណាត់ថ្នាក់ | សម្គាល់ ភាសាខ្មែរ | សម្គាល់ ភាសាអង់គ្លេស | សម្គាល់ ភាសាបារាំង |
|---|---|---|---|---|---|---|
| E3/130 | D366/7.1.187 | លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា | សាធារណៈ | 00442251-00442281 | 00184022-00184047 | 00292914-00292934 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំសាក្សី ឌុច មកកាន់សាលសវនាការ ក្នុងអំឡុងពេលសវនាការពេលរសៀល (១១.០៥)។

00796554



- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី (ម៉ោង ១០.១០) និង នួន ជា (១២.០៣) ទៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរមានភ្ជាប់មកជាមួយកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំសាក្សី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ (១៦.០៤) និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ៩ ព្រឹក នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។

| <u>ការលើកពេលវេលាសវនាការបន្ត៖</u> |
|---|
| សវនាការនឹងបន្តនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលវុទ្ធី Natacha WEXELS-RISER